

# ប្រវត្តសាស្ត្រ អាចទុកជា មេរៀន បានដែរឬទេ ?

ខ្មែរយើង តែងតែចោទជាសំណួរថា ហេតុអ្វីបានជា អ្នកដឹងនាំខ្មែរ នៅតែចាញ់បោកយួន ទោះបីមានប្រវត្តិសាស្ត្រជាតិ ជាចំណេះ សំរាប់បង្ហាញ នូវគ្រប់ឧបាយយួន ធ្វើឧបក្រម រុករានទឹកដីខ្មែរ ច្រើនសតវត្សមកហើយ ? ដោយសារខ្មែរយើង មិនស្គាល់ប្រវត្តិសាស្ត្រជាតិខ្លួនច្បាស់ ឬ មិនយកវា មកទុក ជាមេរៀន សំរាប់ បំភ្លឺផ្លូវអនាគត ?

តែសំណួរនេះ នាំចោទជា បញ្ហាទូទៅ ជាជម្រៅដល់ តួនាទី នៃប្រវត្តិសាស្ត្រ ថាតើគេអាចទុកវា ជាមេរៀនបានដែរឬទេ ?

អ្វីជា មេរៀន គឺ ជាចំណេះចេះដឹង ទុកជាអនុសារ សំរាប់យកវាមកអនុវត្ត តែ ប្រវត្តិសាស្ត្រមិនមែន ជាចំណេះធម្មតា ទោះបីវាមានលក្ខណៈជាវិទ្យាសាស្ត្រ ព្រោះវា ជា ព្រឹត្តិការណ មានកើតឡើងក្នុងអតីតកាល នៅក្នុងបរិបទមួយ ដែលប្រវត្តិសាស្ត្រវិទូ មិនអាចរកឃើញអស់សេចក្តីបាននោះឡើយ។ ហេតុនេះឯង បានជាគេ មិនអាចទុកទាំងស្រុងថា ប្រវត្តិសាស្ត្រ ជា មេរៀន បាននោះទេ តែវា ជាចំណេះ សំខាន់មួយ សំរាប់មនុស្សជាតិ សំរាប់ប្រជាជាតិ ដើម្បី ឲ មនុស្សលោក, ប្រជាពលរដ្ឋ មានសម្បជញ្ញៈ នៃអត្តភាពខ្លួនក្នុងចរន្ត នៃការវិវត្ត នៃមនុស្សជាតិ, ប្រជាជាតិ ដែលខ្លួនកំពុងរស់នៅ។ ចំណេះប្រវត្តិសាស្ត្រ ជាជំនួយ ដល់ជនណាម្នាក់ ដែលមានឆន្ទៈ ស្វែងរកការពិត លើព្រឹត្តិការណ៍អ្វីមួយ ដែលមានកើតឡើង នៅក្នុងអតីតកាល ដើម្បីយល់ដឹង តែ មិនអាចយកវា មកធ្វើជាអនុសារ សំរាប់ ធ្វើតាមបានទាំងស្រុងនោះទេ ព្រោះព្រឹត្តិការណ៍ ដែលមានកើតនៅពេលនោះ វាមានកត្តាច្រើនណាស់ ដែលវាមិនដូចគ្នានឹង កាលៈទេសៈផ្សេងមួយទៀត ទោះបីព្រឹត្តិការណ៍ ដែលកំពុងកើតឡើង វាមានសភាពស្រដៀងគ្នានឹង អ្វីដែលធ្លាប់កើតឡើងក៏ដោយ។ ប្រវត្តិសាស្ត្រ វាមានការពិតរបស់វាតែមួយគត់ តែការពិតនោះជួនកាលវាប្រែច្រើនបែបយ៉ាង មាននៅក្នុងអារម្មណ៍ របស់អ្នកដែលបានអានវា ហើយ យកវាមកបកស្រាយទៅតាម ការយល់ឃើញ ឬ ផលប្រយោជន៍ របស់ខ្លួន។ ឧទាហរណ៍៖ ខ្មែរយើងមានមតិខុសៗគ្នា លើប្រវត្តិសាស្ត្រជាតិ ជាពិសេស លើ ព្រឹត្តិការណ៍នយោបាយ ដែលនាំឲខ្មែរយើងពិបាក រកការពិត ឧបមា ការពិត នៃព្រឹត្តិការណ៍សំខាន់មានកើតឡើងក្នុងសតវត្សទី២០ ដូចជា ព្រឹត្តិការណ៍ ថ្ងៃទី ១៨ មីនា១៩៧០, ១៧ មេសា ១៩៧៥, ៧ មករា ១៩៧៩ ។ល។ ទោះបីព្រឹត្តិការណ៍ទាំងនោះ មានកិច្ចព្រមព្រៀងសន្តិភាព ថ្ងៃទី២៣តុលា ១៩៩១ ជាមូលដ្ឋានច្បាប់ សំរាប់បញ្ចប់ការពិភាក្សាតទល់រកខុសត្រូវជាមតិ រវាងខ្មែរនឹងខ្មែរក៏ដោយ តែគ្រប់ភាគី ពាក់ព័ន្ធ មិនបានយក កិច្ចព្រមព្រៀងនោះ ជាគោលគំនិត ដើម្បីរកឯកភាពជាតិ ក្នុងដំណើរថ្មី នៃការកសាង លទ្ធិប្រជាធិបតេយ្យសេរី។ មានឯក

ដោយ ឧប សៅ សង្ខា
២៧ កញ្ញា ២០១៥

ភាពជាតិ ទើបអាចមាន ប្រវត្តិសាស្ត្រជាតិពិត ពុំនោះសោធ គឺមានតែប្រវត្តិសាស្ត្រ នៃអ្នកឈ្នះ និង អ្នកខ្លាំង តែប៉ុណ្ណោះ ដែលអាចជាប្រវត្តិសាស្ត្រ សិប្បនិម្មិត សំរាប់អ្នកដ៏ទៃទៀត។

ប្រជាពលរដ្ឋនិមួយៗ ត្រូវចេះដឹង នូវប្រវត្តិសាស្ត្រ នៃប្រជាជាតិខ្លួន មិនមែនសំរាប់យកមកធ្វើជាមេរៀន នោះទេ ដូចបានជំរាបខាងលើរួចមកហើយ តែទុកជាការចេះដឹង សំរាប់គិតការពារ លើអ្វីដែលមិនអាចគ្រោងទុក ឧបមា បើប្រវត្តិសាស្ត្រ បានបង្ហាញនូវល្បិចយៀកណាម ធ្លាប់ប្រើសំរាប់លួចទឹកដីខ្មែរ ដូច្នេះខ្មែរយើង ត្រូវមានការប្រុងប្រយ័ត្ន នូវអ្វីដែលធ្លាប់មាន ហើយគិតការពារ ដល់អ្វី ដែលមិនអាចគ្រោងទុក (imprévu) បន្ថែមទៀត ព្រោះល្បិចយកមកប្រើ វាតែងធ្វើនៅក្នុងបរិបទ នៃស្ថានការណ៍ថ្មីជានិច្ច ដូច្នេះការប្រុងប្រយ័ត្ន ដល់អ្វីដែលធ្លាប់មាន វាជាការចាំបាច់ តែវាមិនគ្រប់គ្រាន់ បើគ្មានការគិតដល់អ្វីដែល មិនអាចគ្រោងទុកបាន។ ការគិតនេះហើយដែលជា ចក្ខុទស្សន៍ នៃអនាគត (vision d’avenir) ដែលមានប្រវត្តិសាស្ត្រ និង ស្ថានការណ៍បច្ចុប្បន្ន ជាមូលដ្ឋានរួម សំរាប់យកវាមកគិតពិចារណា ដើម្បីបំភ្លឺផ្លូវអនាគត។

ឧទាហរណ៍ មានច្រើនណាស់ចំពោះខ្មែរ ដែលយើងលើកយកមកបង្ហាញ ជាសង្ខេប នូវព្រឹត្តិការណ៍ ដែលមិនអាចគ្រោងទុក ហើយអ្នកនយោបាយខ្មែរយើងមិនបានយកមកគិតឲបានល្អិតល្អន់៖

១. ឆ្នាំ ១៩៧០៖ ក្រោយពី សភាខ្មែរ បោះឆ្នោតដកសេចក្តីទុកចិត្ត សម្តេច សីហនុ ពីដំណែងប្រមុខរដ្ឋខ្មែរ តើខ្មែរណាអាចជឿបាន ថាព្រះអង្គ ដែលជាខ្មែរមួយរូប ជាអតីតមហាក្សត្រ យកការសងសឹងជាធំ រត់ទៅពឹងយួនយៀកកុង ឲទ័ពគេ វាយប្រហារកងទ័ពជាតិខ្មែរ ដែលនាំឲមានកើតសង្គ្រាមនៅក្នុងស្រុកខ្មែរ។ នេះជា ទង្វើមួយ ដែលមិនអាចគ្រោងទុក តែពេលនោះ បើសិនជា អ្នកនយោបាយខ្មែរ បានគិតដល់វា ថាវានឹងអាចកើតឡើងបាន ប្រហែលជាពួកគាត់មានការប្រុងប្រយ័ត្នជាទ្វេ ដើម្បីរកដំណោះស្រាយណាមួយ ដែលមិនអាចឲទ័ពយៀកកុង ឆ្លៀតឳកាស យកស្រុកខ្មែរ ជាសមរភូមិថ្មីសំរាប់បំរើប្រយោជន៍របស់គេ។ យៀកណាមកុម្មុយនិស្ត គេគិតថា សហរដ្ឋអាមេរិក នឹងជួយខ្មែរពិត តែជាជំនួយរឹតត្បិត ដែលវាគ្មានរំខាន ដល់ការបើកសមរភូមិ នៅស្រុកខ្មែររបស់គេ។ ការគិតរបស់យៀកណាម បែបនេះហើយ ដែលជាការគិតម្ចត់ចត់ លើក អ្វីដែលមិនអាចគ្រោងទុក របស់គេ មុននឹងគេសម្រេច វាយប្រហារកងទ័ពជាតិខ្មែរ ផ្ទុយពីខ្មែរយើងមានជំនឿជាក់ច្បាស់ថា អាមេរិកាំងច្បាស់ជានឹងជួយខ្មែរ ១០០% ដោយមិនយកកត្តានៃនយោបាយ របស់ អាមេរិកាំង ដែលកំពុងរកដំណោះស្រាយ បញ្ឈប់សង្គ្រាមតាមវិធីនយោបាយ គឺការចរចារ ជាមួយ យួន និង លោក កុម្មុយនិស្ត។ ដូច្នេះ សង្គ្រាមរបស់ខ្មែរ ទោះបីមានលក្ខណ:ជាសង្គ្រាមការពារ និង រំដោះជាតិ ពិតប្រាកដ តែវាជាសង្

ក្រោមកាលវិរុទ្ធ ព្រោះវាផ្ទុយ ពីការចង់បាន របស់ សហគមអន្តរជាតិ គឺសន្តិភាពនៅឥណ្ឌូចិន ជាពិសេស ផ្ទុយពី នយោបាយ អាមេរិកាំង នៅដំបន់អាស៊ី គឺ ការបន្ធូរទំនាស់ ដែលមានច្រើន ទស្សវត្សរ៍ ជាមួយចិនកុម្មុយនិស្ត។ តែជំនាន់នោះ តើខ្មែរអ្នកសាធារណៈរដ្ឋនិយម មានជម្រើសដែរឬទេ នៅចំពោះការឈ្លានពាន ដោយអាវុធ របស់យួនកុម្មុយនិស្ត ? ទឹកចិត្តស្នេហាជាតិ និង សេចក្តីក្លាហាន របស់ខ្មែរនៅចំពោះមុខការឈ្លានពានយួនកុម្មុយនិស្តនោះឯង ដែលជំរុញខ្មែរ ឲឆ្លើយតបនឹងអាវុធឈ្លានពាន ដោយអាវុធការពារជាតិ ព្រោះខ្មែរគ្មានជម្រើ នាកាល ដែលអាមេរិកាំង រៀបចំបោះបង់ឥណ្ឌូចិនចោល ទុកឲ យួន និង ចិន កុម្មុយនិស្ត ត្របាក់ស៊ីយ៉ាងងាយស្រួលបំផុត ដែលនាំឲសង្ហារជីវិតខ្មែរ ជាង២លានក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។

២. ឆ្នាំ ១៩៩១៖ នៅក្នុងកិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ ពួកអ្នកនយោបាយមិនមែនកុម្មុយនិស្ត មិនយកកត្តា ដែលមិនអាចគ្រោងទុក គឺ យៀកណាម បំភាន់ ដកកងទ័ព របស់គេចេញពីកម្ពុជា មកគិតសំរាប់ការពារ ដោយសុំទុកកងទ័ព របស់អង្គការសហប្រជាជាតិ ជាអ្នកធានាការពារខ្មែរក្នុងរយៈពេលអន្តរកាល ដើម្បីដាំលទ្ធិប្រជាធិបតេយ្យ។ ការមិនបានគ្រោងទុកនេះឯង ដែលនាំបង្កើតឲមាន រដ្ឋប្រហារ ឆ្នាំ១៩៩៧ ធ្វើឡើងដោយគណបក្សប្រជាជនកម្ពុជា ដោយមានជំនួយពីពួកយោធាយួន លាក់ខ្លួនក្នុងជួរទ័ព របស់គណបក្សប្រជាជន។ តើអ្នកណា ជាអ្នកសុំបញ្ឈប់បេសកកម្មអង្គការសហប្រជាជាតិ មុនពេលកំណត់ទុក ? គឺ សម្តេច សីហនុ។ ព្រះអង្គ ជាកត្តា ដែលខ្មែរមិនមែនកុម្មុយនិស្ត មិនអាចគ្រោងទុក ដូចគ្នានៅឆ្នាំ ១៩៧០ ព្រោះ ព្រះអង្គ បែរជា ទៅធ្វើសហប្រតិបត្តិការ ជាមួយខ្មាំងជាតិ នាកាល ដែលជាតិ ត្រូវការកម្លាំងរួមការពារជាតិ។ សួរថា តើព្រះអង្គ គ្មានជម្រើស ដើម្បីរក្សាសិទិទ្ធពលជាតិ ស្របតាម គំនិត នៃកិច្ចព្រមព្រៀង ២៣ តុលា ? ការដែលមិនបានគិត អ្វីដែលមិនអាចគ្រោងទុកនេះឯង ដែលនាំឲដំណើរលទ្ធិប្រជាធិបេតេយ្យ ទទួលបរាជ័យទាំងស្រុង ទុកឲ យៀកណាម មានលទ្ធភាព រក្សាអំណាចផ្តាច់ការមួយនៅស្រុកខ្មែរ ដែលមានក្រុមយួននៅពីក្រោយ ដែលខ្មែរយើងហៅថា «បាទដៃទី៣» ដើម្បីធ្វើកិច្ចការបំរើប្រយោជន៍របស់គេ។ តើនរណាជាអ្នកទទួលខុសត្រូវ ? អ្នកនយោបាយខ្មែរ មានទម្លាប់ឆក់យកអ្វីដែលជា ភាពភ្លាម ព្រោះវាអាចឲខ្លួនទទួលបាននូវអត្ថប្រយោជន៍ភ្លាមៗ ដែលមានពាក្យបុរាណថ្លែងថា «ឆ្អិតក្បាលស៊ីក្បាល ឆ្អិតកន្ទុយស៊ីកន្ទុយ»។ ឧទាហរណ៍ ដូច សម្តេច សីហនុ ព្រះអង្គ ចង់ធ្វើប្រត្យាស្ថាបនា ភ្លាម របបរាជនិយម សុខចិត្ត ប្តូរនឹង ការរក្សារបប រណបយួន ទោះបីព្រះអង្គដឹងច្បាស់ថា ការដោះដូរបែបនេះ នឹងនាំមក នូវទុក្ខវេទនា ដល់ប្រជាជាតិខ្មែរ។ របបរាជានិយម បច្ចុប្បន្ន គឺដូច គេយកពងមាន់ដែលគេរៃបែករួចហើយ មកផ្គុំ ឲវាទៅជាពងមាន់ឡើងវិញ។ សួរថា តើគេអាចផ្គុំវាបានដែរឬទេ ?

ដោយ ឧប សៅ សង្ហា
២៧ កញ្ញា ២០១៥

ច្បាស់ជាធ្វើមិនបាននោះឡើយ ដូច្នេះត្រូវតែ បង្កើតពងមាន់សិប្បនិម្មិត មានរូបភាពជាពងមាន់ពិត តែគ្មានធាតុជាធម្មជាតិនោះទេ។

នៅមានឧទាហរណ៍ជាច្រើនទៀត តែយើងទុកឲ្យអ្នកអាន ស្វែងរកវា មកពិចារណារៀងៗខ្លួន ព្រោះខ្មែរយើងច្រើន ដឹងរឿងរបស់ប្រជាជាតិខ្លួន ដូច្នេះ មិនចាំបាច់យើងលើកយកបង្ហាញបន្តនោះឡើយ។ យើងគ្រាន់តែលើកជាសំណួរសួរថា តើ គណបក្សសង្គ្រោះជាតិបានគិតពិចារណា លើអ្វី ដែលមិនអាចគ្រោងទុកបានទេ នៅពេលបោះឆ្នោតថ្នាក់ជាតិនាឆ្នាំ ២០១៨ ? ពុំនោះសោធ ច្បាស់ជានាំគ្នាដើរចូលរដ្ឋសភា ជាអ្នករណប គណបក្សប្រជាជន ដូចការដើរចូលក្នុងឆ្នាំ ២០១៤ ជាពុំខាន ដែលជាទង្វើ រំលាយឲបាត់សូន្យ នូវជ័យជំនះ នៃប្រជាពលរដ្ឋខ្មែរ លើ របបផ្តាច់ការ។ សួរថា នៅឆ្នាំ ២០១៨ គណបក្សសង្គ្រោះជាតិ អាចសុំជ័យជំនះ អ្វីម្តងទៀត ពីប្រជាពលរដ្ឋខ្មែរ បើគាត់ភ្លាប់ប្រគល់ឲរួចហើយ ហើយយកជ័យជំនះនោះទៅបោះចោល ដើម្បីកៅអី តែប៉ុណ្ណោះ។ តើបក្សនេះនឹងលើកយក គោលគំនិតអ្វី មកឃោសនា ក្រៅពី «ដូរឬមិនដូរ» តែខ្មែរដឹងថាដល់ពេលប្រជាពលរដ្ឋ ឆ្លើយថា «ដូរ» បែរជានាំគ្នាដូរធ្វើ ការចរចារ ឬ សន្ទនា ទៅវិញ។ តើអ្នកដឹងនាំគណបក្សសង្គ្រោះជាតិ មាន ហិរិ (conscience ce qui est mal) បើខ្លួននៅតាំងខ្លួនជាមនុស្ស ?

## សេចក្តីសន្និដ្ឋាន

ប្រជាពលរដ្ឋ ត្រូវចេះដឹងអំពីប្រវត្តិសាស្ត្រជាតិ តែត្រូវដឹងដែរថា វាមានប្រយោជន៍អ្វី សំរាប់ខ្លួន និង សំរាប់ជាតិ ព្រោះគ្រប់ចំណេះ គឺជាប្រយោជន៍ ដូចចេះអក្សរ សំរាប់អាន. ស្គាល់សីលធម៌ សំរាប់គោរព ។ល។ ចំណេះ នៃប្រវត្តិសាស្ត្រជាតិ ជាការស្គាល់នូវផ្លូវជាតិ ដែលប្រជាជាតិខ្មែរកំពុងបន្តដើរទៅមុខជានិច្ច ដូច្នេះអ្នកដើរមិនអាចវិលត្រឡប់ទៅដើរលើកន្លែងណាដែលខ្លួនធ្លាប់ដើរបានស្រួលនោះឡើយ តែអាចដឹងបានថា ផ្លូវបែបណាដែលពិបាកដើរ ព្រោះធ្លាប់បានដើរនៅកន្លែងនោះរួចហើយ។ ដូច្នេះ បើមិនចង់ឲមានការពិបាកដើរ ត្រូវកសាងផ្លូវ ដែលត្រូវបន្តដើរឲបានល្អ។ ការកសាងនេះឯង ដែលអ្នកកសាងត្រូវការ ការពិសោធ របស់អ្នកដែលធ្លាប់កសាងផ្លូវល្អ។ តែការពិសោធ មិ-មមែនជា ជាមេរៀននោះឡើយ ព្រោះមេរៀនគ្រាន់ជាក្បួន តែក្បួន តែងតែមានកំហិតរបស់វា នៅក្នុងបរិបទ នៃស្ថានភាព។ ដូច្នេះ ចំណេះ នៃប្រវត្តិសាស្ត្រ គឺធ្វើឲអ្នកចេះ មានសម្បជញ្ញៈ លើអ្វីដែលមិនអាចគ្រោងទុក។ ស្គាល់អតីតកាល, រស់នៅក្នុងបច្ចុប្បន្នកាល តែបើគ្មានការគ្រោងទុក ដល់អ្វីដែលមិនអាចគ្រោងទុកបាន គឺ រស់ ក្នុងសភាវគតិ ដែលមានចំណេះ នៃប្រវត្តិសាស្ត្រ មិនមែនជា **សតិជាគរិយៈ** (ដំណើរភ្ញាក់ស្មារតី) ជួននាំបង្កើតក្នុងស្មារតី នូវ **សតិវិប្បវាស** (ការភ្លាត់ឃ្លាតចាកស្មារតី) យកទម្លាប់ទុកជាមាគ៌ា

នៃអនាគត។ ចំណេះ គ្មានសម្បជញ្ញៈ គឺ ជា ទម្លាប់ ដែលអាចសម្លាប់បញ្ញា។ ប្រវត្តិសាស្ត្រ គឺជា សញ្ញាណ នៃប្រជាជាតិមួយ មាន សម្បជញ្ញៈ ជា ប្រជាជាតិ រស់នៅក្នុង សតិជាគរិយៈ ជានិច្ច ដែលជា អាវុធការពារជាតិ ក្នុងស្មារតីជាថាមវ័ន្ត។ ដូច្នេះ **ចិត្តនាការ** (អាការដែលគិត) ត្រូវដឹង អំពី អតីតកាល ត្រូវស្គាល់ បច្ចុប្បន្ន ត្រូវសម្លឹង មើល អនាគត នៅក្នុងសម្បជញ្ញៈ លើអ្វីដែល មិនអាចគ្រោងទុក។

ខ្មែរយើង មានវប្បធម៌ អវិជ្ជមាន មួយ គឺ «វប្បធម៌ ផ្ញើសិន»។ វប្បធម៌នេះឯង ដែលនាំឲខ្មែរ គ្មាន ចិត្តនាការ លើ អ្វីដែលមិនអាចគ្រោងទុក ហើយចេះតែនាំគ្នាសួរខ្លួនឯងបែបជាឆ្ងែឆ្ងល់ថា ហេតុអ្វីបានជាខ្មែរ ចេះតែចាញ់បោកយួនជានិច្ច ?

ដោយ ឧប សៅ សង្ហា
២៧ កញ្ញា ២០១៥